ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## បែបបទ និងនីតិវិធីនៃការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីបែបបទ និងនីតិវិធីក្នុងការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពចំពោះបែបបទ និងនីតិវិធីក្នុងការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## បែបបទ និងនីតិវិធី

**មាត្រា៣ .-**

ក្រោយពីបានទទួលលិខិតពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនូវសេចក្តីសម្រេចចិត្តដាក់ឈ្មោះបុគ្គលឬអង្គភាពក្នុងបញ្ជីដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះ ក្រសួងយុត្តិធម៌ត្រូវបញ្ជូនឯកសារទាំងនោះទៅសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ចដោយគ្មានបង្អង់ដើម្បីស្នើសុំសេចក្តីសម្រេចបង្កកទ្រព្យសម្បត្តិទាំងអស់ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

បន្ទាប់ពីទទួលបានសំណើសុំពីក្រសួងយុត្តិធម៌ សាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ចតាមការកំណត់របស់ក្រសួងយុត្តិធម៌ត្រូវចេញសេចក្តីសម្រេចបង្កកទ្រព្យសម្បត្តិដោយចាត់ទុកជាការប្រញាប់។ សេចក្តីសម្រេចនេះត្រូវធ្វើក្រោមទម្រង់ជាដីកាសម្រេចដោយមានសំអាងហេតុនិងត្រូវអនុវត្តស្របតាមនីតិវិធីនិងច្បាប់ជាធរមាន។

**មាត្រា៤ .-**

ស្របតាមកថាខណ្ឌទី១ នៃមាត្រា៥ នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ជាឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឬព្រះរាជអាជ្ញាអមសាលាដំបូង ដែលមានសមត្ថកិច្ចតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីស្នើទៅតុលាការដាក់ឈ្មោះបុគ្គលឬអង្គភាពក្នុងបញ្ជីនិងបង្កកទ្រព្យសម្បត្តិ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចស្នើសុំ ឬទទួលព័ត៌មាននិងភស្តុតាងពីរាល់ប្រភពពាក់ព័ន្ធក្នុងការកំណត់អត្តសញ្ញាណបុគ្គលឬអង្គភាពដែលពាក់ព័ន្ធនឹងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យដើម្បីស្នើដាក់ឈ្មោះបុគ្គលឬអង្គភាពនោះក្នុងបញ្ជីនិងបង្កកទ្រព្យសម្បត្តិ។

សេចក្តីសម្រេចដាក់ឈ្មោះបុគ្គលឬអង្គភាពក្នុងបញ្ជីនិងបង្កកទ្រព្យសម្បត្តិ ស្របតាមកថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា៥ នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ត្រូវធ្វើក្រោមទម្រង់ជាដីកាសម្រេច។

បុគ្គលឬអង្គភាពឬតតិយជនដែលរងផលប៉ះពាល់ដោយដីកាសម្រេចបង្កកទ្រព្យសម្បត្តិរបស់តុលាការ អាចដាក់ពាក្យបណ្តឹងទៅសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចដើម្បីសុំដកឈ្មោះចេញពីបញ្ជីនិងលុបចោលការបង្កកទ្រព្យសម្បត្តិនោះ។ បែបបទ និងនីតិវិធីនៃការប្តឹងឧទ្ធរណ៍ដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្តក្នុងករណីនេះ។

**មាត្រា៥ .-**

ក្រោយពីបានទទួលដីកាសម្រេចបង្កកទ្រព្យសម្បត្តិដូចមានចែងក្នុងមាត្រា៤ និងមាត្រា៥ នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ បុគ្គលឬអង្គភាពដែលកំពុងកាន់កាប់ទ្រព្យសម្បត្តិត្រូវបង្កកទ្រព្យសម្បត្តិទាំងនោះដោយគ្មានបង្អង់និងដោយគ្មានជូនដំណឹងជាមុនដល់ម្ចាស់ទ្រព្យសម្បត្តិនោះ។

**មាត្រា៦ .-**

ក្រោយពីបានទទួលសេចក្តីសម្រេចចិត្តដកឈ្មោះបុគ្គលឬអង្គភាពចេញពីបញ្ជីដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិឬគណៈកម្មាធិការ នៃក្រុមប្រឹក្សានេះពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ត្រូវបញ្ជូនឯកសារទាំងនោះទៅសាលាដំបូងរាជធានី ខេត្តដែលបានចេញដីកាសម្រេចបង្កកទ្រព្យសម្បត្តិដើម្បីស្នើសុំចេញដីកាសម្រេចលុបចោលការបង្កកទ្រព្យសម្បត្តិ ដោយចាត់ទុកជាការប្រញាប់។

**មាត្រា៧ .-**

សេចក្តីសម្រេចដកឈ្មោះចេញពីបញ្ជីនិងលុបចោលការបង្កកទ្រព្យសម្បត្តិស្របតាមកថាខណ្ឌទី២ នៃមាត្រា៨ នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យត្រូវធ្វើក្រោមទម្រង់ជាដីកាសម្រេចលុបចោលការបង្កកទ្រព្យសម្បត្តិ។

## ជំពូកទី៣
## ទម្រង់របាយការណ៍របស់បុគ្គលក្រៅពីបុគ្គលរាយការណ៍

**មាត្រា៨ .-**

ទម្រង់នៃរបាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដែលត្រូវធ្វើដោយបុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ជំពូកទី៤
## ការរឹបអូសទ្រព្យសម្បត្តិបង្កក

**មាត្រា៩ .-**

សេចក្តីសម្រេចបង្គាប់ឱ្យរឹបអូសទ្រព្យសម្បត្តិដែលត្រូវបានបង្កកស្របតាមកថាខណ្ឌទី២ នៃមាត្រា១៤ នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ត្រូវធ្វើក្រោមទម្រង់ជាដីកាសម្រេចដើម្បីធ្វើការរឹបអូសដោយមានសំអាងហេតុនិងសំអាងច្បាប់។

បុគ្គលដែលអាចត្រូវបានចាត់តាំងដោយតុលាការឱ្យគ្រប់គ្រងមើលចាត់ចែងទ្រព្យសម្បត្តិដែលបានរឹបអូសត្រូវមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិដែលបានរឹបអូសនោះ។

**មាត្រា១០ .-**

ក្រសួងយុត្តិធម៌ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវផ្សព្វផ្សាយជាសាធារណៈនូវសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសេចក្ដីសម្រេចរបស់តុលាការកម្ពុជាស្ដីពីការដាក់ឈ្មោះក្នុងបញ្ជីនិងការបង្កកទ្រព្យសម្បត្តិ និងការដកឈ្មោះចេញពីបញ្ជីនិងការលុបចោលការបង្កកទ្រព្យសម្បត្តិ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៣ កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ